# សិលាចារិកបាលីដែលចាស់ជាងគេនៅកម្ពុជា *

George Coedès †

គេពុំទាន់ដឹងអ្វីច្បាស់លាស់ទេ ថាតើព្រះពុទ្ធសាសនាដែលមានប្រភពមកពីស្រីលង្កា ហើយដែលមានភាសាបាលីជាយាននោះ ករកើតនៅកម្ពុជារបៀបណា។ នៅចុងស.វ.ទី១២ សិលាចារិកនិងសំណង់នានានៃព្រះបាទជ័យវរ្ម័នទី៧ ឲ្យយើងដឹងថា នៅជំនាន់នោះ គេកាន់ព្រះពុទ្ធសាសនាដែលមានភាសាសំស្ក្រឹតជាយាន ហើយទេពដែលលេចមុខជាងគេគឺព្រះលោកេស្វរ[១] និងព្រះភេសជ្ជគ្រូ[២] ។ នៅចុងស.វ.ទី១៣ កំណត់ហេតុនៃលោកជីវតាក្វាន់អាចឲ្យយើងយល់ថា ព្រះពុទ្ធសាសនាដែលមកពីស្រីលង្កាតាមប្រទេសសៀមនោះ ចាក់ឫសរឹងមាំហើយនៅស្រុកខ្មែរ[៣]។

ទាំងនេះមានន័យថា ការផ្លាស់ប្តូរសាសនាយ៉ាងសំខាន់នោះប្រព្រឹត្តទៅនៅស.វ.ទី១៣ តែជាអកុសល សិលាចារិកដែលពាក់ពន្ធ័រឿងនេះមានតិចតួចពន់ប្រមាណ។ បើលើកយកសិលាចារិកដែលលោក Aymonier បានលើកមកបង្ហាញនោះ[៤] ស្ទើរតែគ្មានណាមួយយកជាការបានសោះ។ សិលាចារិកប្រាសាទតាហែម (ខ្លះហៅថាប្រាសាទកំបុត ឬហៅថាប្រាសាទត្នោតជុំខាងជើង, លេខ K.១១៤) ជារបស់ព្រះបាទស្រីន្ទ្រជ័យវរ្ម័នដូច្នោះមែន តែព្រះរាជាអង្គនេះសោយរាជ្យនៅដើមស.វ.ទី១៤ ពោលគឺពុំមែនពីគ.ស.១២២០ ដល់ ១២៥០ ដូចលោក Aymonier ជឿឡើយ[៥]។ សិលាចារិកប្រាសាទតាអាន (K.២៤១) ចារនៅ

---

* ប្រែសម្រួលដោយ អាំង ជូលាន ពីផ្នែកមួយនៃក្រុមអត្ថបទដែលមានឈ្មោះទូទៅថា Etudes cambodgiennes ចុះលេខ XXXII ក្រោមចំណងជើងថា La plus ancienne inscription en pāli du Cambodge នៅក្នុង Bulletin de l'Ecole Française d'Extrême-Orient លេខ XXXLI នៅឆ្នាំ១៩៣៦, ទំព័រ ១៤-២១។

[១] កំណត់អ្នកប្រែ៖ ជាសំស្ក្រឹតគឺ លោកេស្វរ ។

[២] កំណត់អ្នកប្រែ៖ ជាសំស្ក្រឹតគឺ ភៃឞជ្យគុរុ ប្រែថា "គ្រូថ្នាំ" ។

[៣] *BEFEO*, II, p.148, និង XVIII, 9, p.6.

[៤] *Cambodge,* III, pp.610-611.

[៥] *BEFEO,* XXV, p.395.

មហាសករាជ្យ១១៨៩ (គ.ស.១២៦៧) មានពោលតែមួយម៉ាត់អំពីប្រតិមា "កម្រតេងឥជគត៑ សុគតមារវិជិត" ក្រៅពីនោះគ្មានពត៌មានអ្វីទៀតសោះ។ សិលាចារិក ប្រាសាទព្រះធាតុខ្វាវ (K.១៧៧) គ្មានចុះកាលបរិច្ឆេទមែន ប៉ុន្តែការដែលលោក Aymonier យល់ថាចារនៅស.វ.ទី១៣ នោះ ប្រហែលពុំឆ្ងាយពីការពិតដែរ។ ផ្ទុយទៅវិញ សិលាចារិកប្រាសាទក្រឡេង (K.៨៤) ប្រហែលជាចារក្រោយពេលនោះយូរ បើយោងតាមរូបរាងអក្សរ។ រីឯផ្ទាំងអក្សរថ្មមកពីភ្នំបាខែងវិញ (K.២៨៥) ចារនៅមហាសករាជ្យ ១៥០៥ (គ.ស.១៥៨៣)[៦] ។

សិលាចារិកទាំងអម្បាលម៉ាននេះ សុទ្ធសឹងជាភាសាខ្មែរ លាយឡំទៅដោយពាក្យសំស្រ្កឹត ដែលជាទូទៅសរសេរត្រឹមត្រូវ តែពុំមែនលាយឡំនឹងពាក្យបាលីដូចលោក Aymonier ថាឡើយ។ ចំពោះសិលាចារិកបាលីវិញ ក្រៅពីសិលាចារិកវត្តនគរ (K.៨២) ចារនៅមហាសករាជ្យ១៤៨៨ (គ.ស.១៥៦៦) នោះ ខ្ញុំស្គាល់តែអត្ថបទខ្លីមួយប៉ុណ្ណោះ ចារនៅលើស្តម្ភមួយនៅជាន់ខាងលើនៃប្រាសាទអង្គរវត្ត ក្បែរច្រកចូលខាងត្បូងនៃគភ៌គ្រឹះ។ លោក Aymonier[៧] យល់ថាចារនៅស.វ.ទី១៦ ប៉ុន្តែខ្ញុំជឿថាប្រហែលចាស់ជាងនោះបន្តិចទៀត។

ដោយហេតុថាឯកសារខ្សត់ខ្សោយយ៉ាងនេះ ពត៌មានថ្មីអ្វីបន្តិចបន្តួចសុទ្ធសឹងមានសារសំខាន់ទាំងអស់។ ដូច្នេះហើយបានជាយើងចាប់អារម្មណ៍ខ្លាំងណាស់ទៅលើសិលាចារិកមួយដែលគេទើបប្រទះឃើញ[៨] ហើយដែលចារនៅមហាសករាជ្យ ១២៣០ (គ.ស.១៣០៨)។ ប្រៀបនឹងឧទាហរណ៍ឯទៀត ឃើញថាជាឯកសារបាលីដែលចាស់ជាងគេខ្លាំងណាស់នៅប្រទេសកម្ពុជា ហើយពុំតែប៉ុណ្ណោះគឺជាសិលាចារិករបស់ព្រះរាជាទៀតផង ពោលគឺព្រះបាទស្រីន្ទ្រវរ្ម័ន (សូមមើលរូប)។

ទាក់ទងនឹងកាលប្បវត្តិ ព្រះនាមព្រះរាជានេះចោទជាបញ្ហាតូចមួយភ្លាម គឺថាតើសិលាចារិកនៃព្រះបាទស្រីន្ទ្រវរ្ម័ន ចារនៅម.ស.១២៣០ម្តេចកើត បើព្រះអង្គសោយទីវង្គតនៅម.ស.១២២៩?

កាលបរិច្ឆេទ "ម.ស.១២២៩នេះ" បានមកពីលោក L. Finot ដែលបកស្រាយប្រែពីឃ្លាមួយកំបុតខ្ទេចខាត ដោយសារផ្ទាំងអក្សរថ្មនៅប្រាសាទលេខ៤៨៧ (ខ្លះហៅថាប្រាសាទមង្គលាថា) នោះបាក់បែកខ្លះ[៩] ។ នៅល្បះលេខ XLVII (=D11-12) លោក Finot អានថា ៖

> នវ-ទ្វិ-ទ្វិ-ហ្វាធិ ស្វ៌ក្តិ វិជេតុម អក[មន ន្ទបः]
>
> យោវរាជ្យស្ថិតេ ឧត្វា រាជ្យំ យោ ភក---

[៦] ពោលគឺពុំមែនមហាសករាជ្យ១២០៥ ដូចលោក Aymonier យល់ទេ។

[៧] *Cambodge,* III, p.290.

[៨] ពត៌មាននេះធ្លាប់ផ្សព្វផ្សាយនៅក្នុង *BEFEO,* XXX, p.1137។

[៩] *BEFEO,* XXV, p.400.







ផ្ទាំងចារិកនៅ គោកស្វាយចេក, K.៧៥៤
(ក្រដាសផ្តិតEFEO លេខ ៩៥២)

ហើយប្រែថា ៖

> “នៅបណ្តូល_ពីរ_ពីរ_ប្រាំបួន (១២២៩) [ព្រះរាជានេះ = ស្រីន្ទ្រវរ្ម័ន] យាងទៅសួគ៌ ដោយប្រគល់រាជបល្លង្កឲ្យទៅយុវរាជ...”

ប៉ុន្តែបើយកក្រដាសផ្តិតអក្សរថ្មមកពិនិត្យឲ្យល្អិតល្អន់ ឃើញថាច្បាស់គួរសមល្មមនឹងឲ្យអាននៅផ្នែកទី២នៃល្បះនោះថា ៖

> វិជេតុម អគម–ឆម

ដែលយើងអាចបកស្រាយដោយបំពេញកន្លែងថ្មបែកថា ៖

> វិជេតុម អគម[ន វ]ឆម

មានន័យថា ៖

> “ព្រះអង្គយាងទៅព្រៃ ដើម្បីស្វែងរកសួគ៌”

ពោលឲ្យស្រួលស្តាប់គឺ ៖ ព្រះអង្គដាក់រាជ្យឲ្យទៅព្រះយុវរាជ ហើយយាងទៅគង់ជាតាបសឫសី ដើម្បីសាងបុណ្យទៅកាន់សួគ៌លោក។

ដូច្នេះ កាលបរិច្ឆេទនោះពុំមែនជាឆ្នាំដែលព្រះបាទស្រីន្ទ្រវរ្ម័នសោយទីវង្គត ដូចលោក Finot ធ្លាប់គិតឡើយ តែគឺជាឆ្នាំដែលព្រះអង្គដាក់រាជ្យ មិនខុសអ្វីពី១១ឆ្នាំមុននោះ ដែលព្រះបាទជ័យវរ្ម័នទី៨_បរមេស្វរ[១០] ជាព្រះបិតាក្មេកធ្លាប់ដាក់រាជ្យប្រគល់មកព្រះអង្គដែរ[១១] ។ ហេតុនេះគ្មានអ្វីប្លែកទេ ដែលយើងឃើញព្រះនាមព្រះបាទស្រីន្ទ្រវរ្ម័ននៅសិលាចារិកមួយទៀតនៅ ម.ស.១២៣០ ក្បិតពេលនោះព្រះអង្គនៅមានព្រះជន្មនៅឡើយ គ្រាន់តែលែងសោយរាជ្យ។

ផ្ទាំងសិលាចារិកដែលពោលនេះ មានអក្សរនៅសងខាង (កំពស់ ១.៧០ម, ទទឹង០.៤៩៥ម) ហើយលោក G.Trouvé បានរកឃើញនៅខែកុម្ភៈ ឆ្នាំ១៩៣៣ នៅវត្តគោកខ្ពស់ ដែលស្ថិតនៅប្រមាណ៨០០ម ខាងត្បូងវត្តប្រាសាទ[១២] ។ តាមពុទ្ធដីកាព្រះសង្ឃ ថ្មនេះបានមកពីទួលមួយហៅថា “គោកស្វាយចេក” នៅចម្ងាយប្រមាណ ៣គ.ម. ខាងនិរតីវត្ត[១៣]។

ចារិកនៅលើផ្ទាំងម្ខាងជាភាសាបាលីមានទាំងអស់២០បន្ទាត់ ត្រូវនឹង១០ល្បះ។ ផ្ទាំងម្ខាងទៀតមានសេចក្តី៣១បន្ទាត់ជាភាសាខ្មែរ។

---

[១០] កំណត់អ្នកប្រែ ៖ ជាសំស្ក្រឹតគឺបរមេក្ស្វរ។

[១១] *BEFEO,* XXV, p.395.

[១២] នៅតំបន់មួយស្ថិតនៅខាងត្បូងបារាយខាងលិច។ សូមអាន de Lajonquière, *Inventaire*, III, p.280, nº 581។

[១៣] សិលាចារិកគោកស្វាយចេក មានលេខដំរៀប K. ៧៥៤ នៅក្នុងបញ្ជីសិលាចារិកកម្ពុជា។

សិលាចារិកនេះ ចាស់ជាងនៅប្រាសាទមង្គលាថិនិងសិលាចារិកអង្គរវត្តលេខ K.៣០០ ក៏ពិតមែន តែអក្សរមានការវិវឌ្ឍន៍មកឆ្ងាយជាង ហើយពិនិត្យមែនទែនទៅ ឃើញថាចាប់ផ្តើមងាកទៅរកប្រភេទមួយដែលក្រោយមករីកដុះដាលក្លាយមកជាអក្សរចារលើសាស្ត្រាស្លឹករឹតដូចយើងធ្លាប់ស្គាល់។

ពាក្យបាលីនោះ ផ្តើមដោយការសម្បូងសម្រូងទៅព្រះត្រ័យរត្ន។ បន្ទាប់មកទើបបង្ហាញព្រះនាមព្រះបាទសិរិសិរិន្ទវម្ម ដែលបានឡើងគ្រងរាជ្យនៅក្រុងយសោធរ នៅម.ស.១២១៨ (គ.ស.១២៩៦) ។នៅម.ស.១២៣០ (គ.ស.១៣០៨) ព្រះអង្គប្រទានភូមិ សិរិសិរិន្ទរតនគាម ទៅព្រះមហាថេរ សិរិសិរិន្ទមោឡិ។ ព្រះអង្គត្រាសបង្គាប់ទៅឧបាសិកាម្នាក់ឈ្មោះ សិរិមាលិនីរតនលក្ខី ឲ្យសាងព្រះវិហារមួយ[១៤]។នៅម.ស.១២៣១ (គ.ស.១៣០៩) ឧបាសិកានោះរៀបចំតម្កល់ព្រះពុទ្ធរូបព្រមទាំងទ័យទានផ្សេងៗ។ ក្នុងឱកាសនោះ ព្រះរាជាបានដាក់ងារទៅដល់ភូមិ៤ឲ្យផ្គត់ផ្គង់ឧបត្ថម្ភវត្តនោះ។

អត្ថបទខ្មែរក៏និយាយរឿងប្រហាក់ប្រហែលគ្នាដែរ តែក្បោះក្បាយជាងពាក្យបាលី ហើយឈ្មោះនានាបង្ហាញជាឈ្មោះសំស្ក្រឹត ៖ ក្រីក្រីន្ទ្រវរ្ម័ន, ក្រីក្រីន្ទ្រមៅលិទេវ, ក្រីក្រីន្ទ្ររត្នគ្រាម, ក្រីមាលិនីរត្នលក្ស្មី។ រីឯព្រះពុទ្ធរូបដែលផ្នែកបាលីពុំមានបង្ហាញព្រះនាមនោះ នៅខាងខ្មែរមានបញ្ជាក់ព្រះនាមថា ក្រីក្រីន្ទ្រមហាទេវ។ យើងឃើញថានាមនោះដាក់តាមព្រះនាមព្រះរាជា តាមទំនៀមដែលធ្លាប់មានអំពីមុននោះរៀងមក ដែលតែងតែភ្ជាប់មនុស្សទៅនឹងទេពក្នុងព្រហ្មញ្ញសាសនា ឬទៅតាមព្រះពោធិសត្វលោកេស្វរ ដោយហៅថា “កម្រតេង៍ជគត៑”។ ផ្នែកខ្មែរនេះមានរាប់ឈ្មោះភូមិស្រុក, ពន្ធអាករដែលត្រូវទារ, ខ្ញុំបម្រើព្រមទាំងរបស់របរដែលប្រគេនទៅវត្ត ហើយជាបញ្ចប់មានបញ្ជាក់ថា ដីធ្លីដែលយកមកសាងវត្តនោះ បានមកដោយរបៀបណា។

អំណើះតទៅ ដោយសារសិលាចារិកនេះ យើងមានសក្ខីកម្មច្បាស់លាស់ថា នៅដើមស.វ.ទី១៤ មានព្រះពុទ្ធសាសនាដែលប្រើបាលីជាយាន ហើយដែលទទួលការឧបត្ថម្ភទំនុកបម្រុងពីព្រះរាជាមួយអង្គ ដែលតាមស្មានមើលទៅប្រហែលជាដាក់រាជ្យដើម្បីប្រតិបត្តិសាសនានោះឲ្យកាន់តែខ្ជាប់ខ្ជួនប្រសើរ។

អត្ថបទ

ផ្ទាំង “ក”

I- ១–វិសុទ្ធម អវិសុទ្ធានំ　　សុទ្ធិសម្បាបកញ្ញ ជិនំ

　២–ធម្មញ្ញ ចារិយសង្ឃញ្ញ ច　　សតតំ សិរសា ឧមេ។

II- ៣–សិរិសិរិន្ទវម្មាខ្យ–　　ភូបេសោ កុណាភូសនោ

　៤–យសោធរបុរេ អាសិ　　មង្គលិន្ទុយមិន្ទុនា។

---

[១៤] កំណត់អ្នកប្រែ ៖ ពាក្យថា “វិហារ” នៅទីនេះហាក់ដូចជាសំដៅថា វត្តមួយទាំងមូល។

| | | |
|---|---|---|
| III- | ៥–នភក្តិយមចន្ទម្ហិ | អស្សិនីតារកាឝ្ចិតេ |
| | ៦–រវិវារម្ហិ តតិយេ | យាមេ តីតេ ទ្វិចានកេ។ |
| IV- | ៧–សិរិសិរិន្ទមោទ្បិស្ស[15] | មហាថេរស្ស ធីមតោ |
| | ៨–សិរិសិរិន្ទរតន– | កាមម៍ ឋតំ អនា មុនា។ |
| V- | ៩–សិរិមាលិនីរតន– | លក្ខី នាម ឧចាសិកា |
| | ១០–សទ្ធាទិគុណសម្បន្នា | រាជាលង្ការចាលកា។ |
| VI- | ១១–បេសិតា តេន កា រេត្វា | វិហារម ឥធ សា បុន |
| | ១២–បរិខញ្ច តដាកញ្ច | ខណាបេត្តី តតោ បរំ។ |
| VII- | ១៣–ចន្ទគ្គិយមចន្ទម្ហិ | ភូចាធិបតិបេសិតា |
| | ១៤–ពុទ្ធរូបណា[16] ដ្ឋាចាបេត្វា | ធាសិធាសាទិកេ អនា។ |
| VIII- | ១៥–វកុលត្តលកាមញ្ច | ធំធាម្ហយកាមកំ |
| | ១៦–ធាលិសត្តលកាមញ្ច | ឆទ្យគ្គគ្គាមកញ្ចិមេ។ |
| IX- | ១៧–ពន្ទេន្តោ ខេត្តសីមាយោ | សមន្តដ្ឋធិសាសុ ច |
| | ១៨–ពុទ្ធបូជាយ ចាធាសិ | ភូចាធិបតិ ធម្មិកោ។ |
| X- | ១៩–សិរិសិរិន្ទរតន– | កាមក្ខេត្តានម អន្តរេ |
| | ២០–អដ្ឋបត្តីនិ ខេត្តានិ | យាជកានម អនាបយិ។ |

អត្ថបទ

ផ្ទាំង "១"

(១) ១២៣០ កក នវមី កេត៌ បុប្យ អាទិត្យវារ អក្និនី នក្ស–

(២) ត្រ ចាន វ្យ៌ តិ[17] ស្រចិ ត្វតិយ គិ នុ ព្រ(ះ) ករុណា ត បរមបវិ–

[15] តួអក្សរ ឡ បានមកពីអក្សរ ឌ ដែលមានជើង ដ ។

[16] សូមសង្កេតមើលសន្ធិ។

[17] ឬមួយប្រហែលជា គិ ។

(៣) ត្រ៑ ព្រះ ចាន កម្រតេង៑ អញ៑ ឝ្រីឝ្រីន្ទ្រវម៌្មទេវ៑។

(៤) ប្រេ ចារ៑ ឝិលាប្រឝស្ត ករាក ត គិ ស្រុ(ក៑) អំពៅ ស្រុក៑ ចុង៑ ង្គុ

(៥) (ង៑) ឆា ជេង៑ ឆល[18] ត្រិឈាំ ជៅ ឲ្យ ស្រុក៑ ស្មោង៑ ឲ្យ ឆាម ស្រុ

(៦) (ក៑) ឝ្រីឝ្រីន្ទ្រវតនគ្រាម ប្រេ កម្រតេង៑ អញ៑ ឝ្រីមាលិនិវតនលក្ឞ្មី

(៧) ព្រះ ដ្ឋំ សំរច[19] វិហារ សំនិង៑ ជ្យក៑ អញ្ចុង៑ ទន្លេ / ១២៣០ កក ប្អា–

(៨) បក ព្រះ វុទ្ធ កម្រតេង៑ អញ៑ ឝ្រីឝ្រីន្ទ្រមហាទេវ ប្រសាទ ត ម–

(៩) ហាស្វាមី ជេរ ឝ្រីឝ្រីន្ទ្រមៅលីទេវ ជា សង្កល្ប បំរេ ត កម្រតេ–

(១០) ង៑ អញ៑ ភិក្ខុសង្ឃ ដោង៑ / ស្រុក៑ ជំនូង៑ ត បង្គង៑ សំរប៑ ព្រះ វុ–

(១១) ទ្ធយជ្ង ស្រុក៑ ធំនាំ ចំនត៑ គោក៑ វកុល គោក៑ សំលាញ៑ ស្រែ

(១២) ភ្វមិ បន្សំ នោះ បំរេ ធិន រង្គ លិះ ច្រាំ // ស្រែ កម្រតេង៑ អញ៑

(១៣) ត សិង៑ ប្រតិបក្ឞ ជំ ប្រំបីយ៑ កំលុង៑ ស្រុក៑ ឝ្រីឝ្រីន្ទ្រវតនគ្រាម / ត

(១៤) ចំអិន ព្រះវុទ្ធយជ្ងតៃ លក្ឞ្មី បេះ[20] វ្យ យង្វាង៑ បំរេ ឝិ លាង៑ / ត

(១៥) ជ្វេ ព្រះ វុទ្ធប្ជា គិ កង្គាក្ម៌ តៃ សុខរត្ន អាត្មជ ឝី តេ[21] ៗតៃ

(១៦) ដ្បាយ៑ ម្វយ៑ ក្ឞីរាយត ម្វយ៑ ។ តីរាត គ្រោង៑ ដ្វំម៑ ប្រំបីយ៑។

(១៧) គោ ចន្ទត៑ គោក្រ្យារ៑ ឆ្នំម៑ ប្រំបិយ៑ ក្របី យី ជ្នាល៑ ឆ្នំម៑ វ្យារ៑ លា

(១៨) ម្វយ៑។ សង្ខ សុក្ត វ្យារ៑ អង្គិសង្ខ សារិត៑ ម្វយ៑ អយ្ឞ៌ ចាន្យ វង្គិណា ដ្វំម៑ ប្វង៑។

(១៩) កលស ស្រង៑ ម្វយ៑ តំ ង្វាង៑ ច្រាក៑ ម្វយ៑ កជក មោទរី[22] ច្រាក៑ សំរប៑ ម្វ–

---

[18] អក្សរ ឆ នេះ បើគិតថាជាអក្សរ ធ វិញក៏អាចថាបាន។

[19] ឬមួយប្រហែលជា *សំរេច ?*

[20] កំណត់អ្នកប្រែ ៖ ស្រះ "េ" ត្រង់នេះ លោក Coedès និយាយថា មានរូបរាងពិសេស គឺពុំមែនស្រះ "េ" ហើយពុំមែនជាស្រះ "ៃ" ដែរ។ លោកបញ្ជាក់ថា នេះជាដានឬតម្រុយឲ្យយើងដឹងថា ជំនាន់នោះមានសម្លេង "ែ" ហើយ។ លោក Coedès មានធ្វើការបកស្រាយវែងឆ្ងាយ ដោយប្រៀបធៀបទៅនឹងពាក្យសៀមផង ព្រមទាំងទៅសិលាចារិកសម័យកណ្ដាលនៅអង្គរវត្តផង។

[21] កំណត់អ្នកប្រែ ៖ ចំពោះស្រះ "េ" នៅត្រង់នេះ សូមមើលសេចក្ដីសង្កេតនៅកំណត់យោងមុននេះ *(លេខ២០)*។

[22] ព្យាង្គទីមួយ អាចអានខុស ហើយអាចចាប់ផ្ដើមដោយ "ចោ", "វោ", "ហោ" ក៏មិនដឹង។

(២០) យ៑ គន្ធី ត្រប្វ ម្វយ៑ គមណ្ឌលុ សំរប៑ ម្វយ៑ ភាជន លង្គៅ ម្វយ៑ ជេង៑ ប–

(២១) ឆ្នំ កោស ត្រប្វ ប្វន៑ គ្រែង៑ វ្យរ៑ ត្យល៑ វ្យរ៑ បន្ទង៑ ម្វយ៑ ជវនិកា ម្វ–

(២២) យ៑ កុសុម្ភ វ្យរ៑ ថាន រុង៑ វ្យរ៑ ស្គរ៑ ម្វយ៑ តាល ឆន្ទ បន្ទំ ស្រែ ភ្វមិ

(២៣) ចង្វត៑ ស្រុក៑ រោះ ត ជីកា / ប្វវ៑ ប្រសប៑ គោល៑ / អាគ្នេយ ប្រសប៑ គោ–

(២៤) ល៑ ទក្សិណ ប្រសប៑ គោល៑ នៃឫតិយ ប្រសប៑ គោល៑ បក្ខិម ប្រសប៑

(២៥) គោល៑ វាយវ្យ ប្រសប៑ គោល៑ ឧត្តរ ប្រសប៑ គោល៑ ឦសាន្យ ប្រសប៑

(២៦) គោល៑។ នេះ ស្រុក៑ អំបោ នា វ្រះ កត្តិ កម្រតេង៑ អញ៑ សុវណ្ណលិ–

(២៧) ង្គ ដ្សង៑ និ ប្រែ ជៅ នុ ថាស៑ ឆ្កិន៑ លិង៑ បិយ៑ ឲ្យ ស្រុក៑ លុន៑ ស្នោង៑

(២៨) សោត៑ ស្រុក៑ ធំនាំ ចំនត៑ បន្ទំ នា វ្រះ ស្រុក៑ សំឫទ្ធិបុរ ដ្សង៑ និ ប្រែ ឱ–

(២៩) យ៑ ស្រុក៑ កនកភាគ វិង៑ ស្នោង៑ ស្រុក៑ ចុង៑ ឆ្គង៑ ដ្សង៑ និ ប្រែ ឲ្យ

(៣០) ស្រុក៑ វ្រះ ឦត៑ វិង៑ ស្នោង៑ នា ថ្ងៃ វ្រះ វង្គ ត គិ …

(៣១) គី ទ្វិត៑ សោត៑ ឆ្នំ…

ប្រែ

ផ្ទាំង “ក”

I- ខ្ញុំឱនសិរសា ឥតបីអាក់ចំពោះព្រះជិនស្រី ដែលព្រះអង្គធ្វើឲ្យមន្ទិលក្លាយជាបរិសុទ្ធ, ចំពោះព្រះធម៌ និងព្រះសង្ឃ។

II- នៅយសោធរបុរ នាព្រះចន្ទ្រ (១) - គូ (២) - ព្រះចន្ទ្រ (១) - វត្ថុមង្គល (៨) មានព្រះរាជាមួយអង្គប្រកបដោយគុណសម្បត្តិ មានព្រះនាមថា សិរិសិរិន្ទវម្ម។

III- នាព្រះចន្ទ្រ (១) - គូ (២) - ភ្លើង (៣) - មេឃ (០) នៅក្រោមផ្កាយអស្សិនី, ថ្ងៃអាទិត្យ, ២បាទក្រោយយាម ៣ចប់សព្វគ្រប់

IV- ព្រះអង្គសព្វព្រះទ័យប្រទានភូមិសិរិសិរិន្ទរតនគាមដល់ព្រះមហាថេរ សិរិសិរិន្ទមោឡី។

V- ឧបាសិកាឈ្មោះសិរិមាលិនីរតនលក្ខីដែលប្រកបដោយសទ្ធានិងគុណសម្បត្តិនានា ហើយដែលជាអ្នករក្សាព្រះរាជអលង្ការ

VI- បានសាងម្តងទៀតនូវព្រះវិហារមួយទៀតតាមព្រះរាជបញ្ជា ហើយបន្ទាប់មកបានជីកគូនិងស្រះទឹក។

VII- នាព្រះចន្ទ្រ *(១)* - គូ *(២)* - ភ្លើង *(៣)* - ព្រះចន្ទ្រ *(១)* តាមព្រះរាជបញ្ជា ឧបាសិកាបានសាងព្រះពុទ្ធប្រតិមា ព្រមទាំងថ្វាយខ្ញុំស្រីប្រុស និងតង្វាយដទៃទៀត។

VIII- ភូមិទាំងនេះឈ្មោះ ពកុលត្ថល, ទំទាម, តាលីសត្ថល និង នទ្យគ្គ[២៣]

IX- គឺព្រះរាជាដ៏មានសទ្ធាបានកំណត់ព្រំតាមទិសទាំងប្រាំបី សម្រាប់កិច្ចបូជាព្រះពុទ្ធអង្គ។

X- ក្នុងបរិវេណភូមិ សិរិសិរិន្ទ្ររតនគាម ព្រះអង្គបានប្រទានដីប្រាំបីកន្លែងដល់បុព្វជិតជាអ្នកធ្វើកិច្ច។

ផ្ទាំង “១”

[កំណត់អ្នកប្រែ ៖]

[សូមអ្នកអានកុំភ្លេចថា លោក G.Coedès ប្រែសិលាចារិកខ្មែរជំនាន់ដើមស.វ.ទី១៤ នេះមកជាបារាំង។ ដូច្នេះរបៀបរៀបឃ្លោងឃ្លា គឺធ្វើឡើងតម្រូវទៅតាមវេយ្យាករណ៍និងរបៀបដែលបារាំងរៀបចំឃ្លា។ ឯខ្ញុំជាអ្នកប្រែអត្ថបទលោក Coedès ទាំងមូលពីបារាំងមកខ្មែរនោះ ពុំអាចភ្លេចថាពាក្យដើមនៅទីនេះជាខ្មែរទេ។ ដូច្នេះ ចំពោះន័យទាំងអម្បាលម៉ាន ខ្ញុំតម្រូវសេចក្តីប្រែតាមលោក Coedès ទាំងស្រុងមែន ប៉ុន្តែឃ្លាប្រែវិញ ខ្ញុំត្រូវសម្រួលឲ្យជិតនឹងពាក្យដើម។ មួយវិញទៀត កំណត់យោងលោក Coedès មានច្រើនស្អែកស្អះ ដែលខ្ញុំពុំអាចយកតាមទាំងស្រុងបាន។ ហេតុមានច្រើនបែបយ៉ាង។ ឧទាហរណ៍ លោក Coedès បញ្ជាក់អ្នកអានថា កាលណាពាក្យខ្មែរក្នុងសិលាចារិកថា “ស្រុក ” លោកជាប្រែបារាំងថា “Village” ដោយពុំរើសមុខ។ ឯខ្ញុំវិញ គ្មានហេតុផលអ្វីចាំបាច់នឹងប្រាប់ថា ប្រែ “ស្រុក” ទៅជា “ស្រុក” ដូច្នេះឡើយ ព្រោះជាពាក្យខ្មែរតែមួយស្រាប់។ ជួនកាលលោក Coedès ប្រៀបពាក្យខ្មែរទៅពាក្យសៀម ដោយសរសេរអក្សរជារ៉ូម៉ាំង ហើយមានសក់ស្អែកស្អះ ដែលយើងពុំអាចធ្វើនៅទីនេះបាន។ យ៉ាងណាក៏ដោយ កំណត់យោងក្នុងសេចក្តីប្រែផ្ទាំង “១” ជាខ្មែរទំនើបនេះ មិនដូចគ្នាបេះបិទនឹងសេចក្តីជាបារាំងឡើយ។]

*មហាសករាជ្យ ១២៣០, ៩កើតខែបុស្ស, ថ្ងៃអាទិត្យ, នក្សត្រអស្វិនី, ២បាទបន្ទាប់ពីយាមទី៣[២៤],*
*ព្រះករុណាបរមបពិត្រ ព្រះបាទស្រីស្រីន្ទ្រវម៌ ត្រាស់បញ្ជាឲ្យចារសេចក្តីលើថ្ម[២៥] នៅស្រុកអំចៅ*

[២៣] ជាខ្មែរ ភូមិទាំងនេះមានឈ្មោះថា គោតិវកុលិ, ធំទាំ, គោតិសំលាញ៉ និង ចុនិជ្ជិនិ។

[២៤] ប្រែនេះ គឺដោយផ្គូផ្គងទៅពាក្យបាលីដែលថា តតិយេ យាមេតីតេ។

[២៥] ប្រសម្ម នេះច្បាស់ជាសរសេរក្លាយមកពី ប្រកស្ត ហើយ។ ករាគ ពុំដឹងថាជាអ្វីប្រាកដទេ តែប្រហែលមានន័យស្រដៀងនឹងពាក្យនិយាយសព្វថ្ងៃថា ប្រសេដ្ឋសក្តិ *(កំណត់អ្នកប្រែ ៖ ខ្ញុំពុំច្បាស់ថា លោក Coedès ប្រើពាក្យនេះមែនឬទេ គឺគ្រាន់តែជាការស្មានប៉ុណ្ណោះ។ សូមពិនិត្យអត្ថបទដើមជាបារាំង ត្រង់ទំព័រ១៩, កំណត់យោងលេខ១២)* ដែលសំដៅថា “ ខ្ពង់ខ្ពស់” ក៏មិនដឹង។

និងស្រុកចុងធ្មិង[២៦] (ជាចំណុះតំបន់) ទីបីនៃ---[២៧] ដែលបានមកដោយយកស្រុក (ដទៃទៀត) ធ្វើថ្នូរ[២៨] ហើយដែលឲ្យឈ្មោះថាស្រុកស្រីស្រីន្ទ្រវត្តគ្រាម។ (ព្រះរាជា) ត្រាស់បង្គាប់ទៅព្រះគម្តែងស្រីមាលីនិវត្តលក្ស្មី (ដែលបម្រើការនៅក្នុងក្រុមរក្សា) ព្រះអលង្ការ[២៩] ឲ្យសាងព្រះវិហារមួយ (សម្រាប់ព្រះសង្ឃ) គង់[៣០] ហើយជីកស្រះតូចធំ[៣១] ។

នៅម.ស.១២៣០[៣២] (ព្រះរាជា) សាងព្រះពុទ្ធរូប ព្រះនាមស្រីស្រីន្ទ្រមហាទេព ហើយប្រគេនទៅព្រះមហាស្វាមីថេរ (ព្រះនាម) ស្រីស្រីន្ទ្រមៅលីទេព ដោយព្រះទ័យប្រាថ្នាសូមទំនុកបម្រុងព្រះគម្តែងសង្ឃទាំងពួង។ ស្រុកដែលប្រោសប្រទានជាតង្វាយសម្រាប់ផ្គត់ផ្គង់ពុទ្ធបូជាមានស្រុកទំទាំ, ចំនត៑[៣៣] គោកិ៑វកុលិ៑ និងគោកិ៑សំលាញ៑[៣៤]។ ភោគផលបានមកពីស្រែនិងដីទាំងប៉ុន្មានត្រូវផ្សុំគ្នាដើម្បីផ្តល់អង្ករ៩លិះក្នុងមួយថ្ងៃ។ ស្រែព្រះគម្តែងសង្ឃ[៣៥] ដែលគង់ក្នុងបក្ស[៣៦] នីមួយៗ ៖

[២៦] និយាយតាមសព្វថ្ងៃគឺ " ចុងស្ទឹង " ។ ឈ្មោះនេះត្រូវនឹងឈ្មោះជាបាលីថា ឆន្ទ្យគ្គ។

[២៧]កន្លែងនេះមើលមិនច្បាស់សោះ។ ដេនិឆលិ (ឬ ឆលិ) ធ្វើឲ្យនឹកទៅដល់ ដេនិឈលិ ក្នុងឈ្មោះមេទ័ពសៀមម្នាក់ ដែលឃើញនៅផ្ទាំងចម្លាក់អង្គរវត្ត (សូមអាន *BCAI,* 1911, p.203) ។

[២៨] ន័យដែលស្នើនេះ យ៉ាងណាក៏ស្របទៅនឹងសេចក្តីពីបន្ទាត់លេខ២៦ ដល់លេខ៣០ដែរ។

[២៩] សព្វថ្ងៃហៅថា "ធ្នឹម" ដូចពាក្យសៀមដែរ គឺត្រូវនឹងពាក្យថា រាជាលង្ការ (ទាលង្កា ក្នុងបាលី)។

[៣០] កំណត់អ្នកប្រែ ៖ នៅទីនេះយើងឃើញថា ដែលហៅថាព្រះវិហារ គឺសំដៅលើវត្តទាំងមូល។ សូមមើលកំណត់យោងលេខ ១៤។

[៣១] កំណត់អ្នកប្រែ ៖ ពាក្យដើមថា អត្រាធិ ឌន្ទេ ដែលសំដៅលើស្រះទឹកតូចនិងត្រពាំងដែលមានទំហំធំ។

[៣២] ចារិកជាបាលីដាក់ថា "១២៣១"។ កាលបរិច្ឆេទ ១២៣០នៅទីនេះ គឺច្បាស់ជាឲ្យប្រទ្បំហើយ ព្រោះគ្មានហេតុផលអ្វីនឹងនិយាយដដែលដូច្នេះទេ បើសិនជាការសាងព្រះវិហារនិងការសាងព្រះពុទ្ធរូបធ្វើនៅឆ្នាំជាមួយគ្នានោះ។

[៣៣] កំណត់អ្នកប្រែ ៖ ចំនត៑ សំដៅលើ ភូមិស្រុកអ្វីមួយដែលកំពុងរៀបចំបង្កបង្កើតឡើង ឬដែលទើបនឹងចេញជារូបរាងឡើង។

[៣៤] គោកិ៑វកុលិ៑ត្រូវនឹងបាលី វកុលត្ថល ឯ គោកិ៑សំលាញ៑ត្រូវនឹង តលីសត្ថល ប៉ុន្តែជនជាតិខ្មែរសព្វថ្ងៃ ដូចជាភ្លេចពាក្យខ្មែរដែលត្រូវនឹងបាលី តាលីស (Flacourtia cataphracta) នោះហើយ ព្រោះប្រើពាក្យសៀមតាខុប ជំនួស សំលាញ៑ វិញ។ កំណត់អ្នកប្រែ ៖ នៅទីនេះ ប្រហែលលោក Coedès យល់ខុសក៏មិនដឹង ត្បិតសំឡាញជាពាក្យដែលខ្មែរនៅតំបន់ខ្លះ (ឧទាហរណ៍នៅតំបន់ភ្នំក្រវាញ) ហៅដើមទ្រាំង (Corypha lecomtei)។

[៣៥] គម្រតេងអញ៑ នៅខាងលើសំដៅក្រុមសង្ឃទាំងមូល។ នៅទីនេះ គឺត្រូវនឹងពាក្យ យាជក នៃផ្នែកបាលី។ គេដឹងថាពាក្យនេះត្រូវនឹងពាក្យសៀមថា "ចៅឃូ" ពោលគឺពាក្យដែលលោក ជីវ តាក្វាន់ សំដៅលើព្រះសង្ឃនៅកម្ពុជា ហើយដែលភាសាមនហៅថា Trala poi ដែលក្លាយមកជាបារាំងថា "Talapoin"។ យើងសង្កេតឃើញថា គេធ្វើការដោយគិតតាមបក្ស ខ្នើត_រនោច ដូចការចាត់ចែងការងារក្នុងព្រាហ្មណ៍សាសនាដែរ។

[៣៦] កំណត់អ្នកប្រែ ៖ ពេញមួយខ្នើត ឬពេញមួយរនោច។

៨ជំ[៣៧]ក្នុងស្រុកស្រីស្រីន្ទ្ររតនគ្រាម។ អ្នកចំអិនក្រយាព្រះ គឺតៃ[៣៨]លក្ខី, អ្នកបេះផ្កាយផ្លាង៑[៣៩] គឺសិលាន៑[៤០], អ្នកបម្រើបូជាព្រះ គឺសិគង្គាកម្មិ[៤១], តៃសុខរត្ន និងសិកេ ដែលត្រូវជាកូន, តៃផ្យាយ៑[៤២], អ្នករិតទឹកដោះម្នាក់, អ្នកភ្ញុំម្នាក់ឈ្មោះគ្រោង។ សារុបមកមាន៨អ្នក។ គោ[៤៣] និងគោក្រៀវ ៨នឹម, ក្របីញីឈ្មោល២នឹម[៤៤], លា១, សង្ខ័ពណ៌ស ២[៤៥], អទ្រិសង្ខ័សំរិត១[៤៦], អឃ៌្យ, បាទ្យ, វទ្ធិ៌ណី[៤៧](៖) ទាំងអស់នេះមាន ៤។ កំសៀវទឹកស្រង់, ដើមផ្លាង៑ធ្វើពីប្រាក់[៤៨], កង១សម្រាប់ ធ្វើពីប្រាក់, គន្ទី១ ធ្វើពីសំណប៉ាហាំង, ក្អម១ សម្រាប់, ភាជន៍ស្លាន់១ មានជើង[៤៩],

[៣៧] ខ្ញុំមិនដែលប្រទះពាក្យដែលប្រហែលជាសំដៅលើទំហំផ្ទៃដីនេះទេ។ ជំ ៨នេះត្រូវនឹងខេត្ត៨នៅក្នុងពាក្យបាលី (ល្បះទី១០)។

[៣៨] តៃ សំដៅលើខ្ញុំស្រីដែលនៅបម្រើតាមប្រាសាទ។

[៣៩] កំណត់អ្នកប្រែ ៖ ត្រង់នេះលោក Coedès ធ្វើកំណត់យោងវែងឆ្ងាយមួយដើម្បីរកន័យពាក្យ "យផ្លាង៑" ដោយធ្វើការប្រៀបធៀបវែងឆ្ងាយជាមួយពាក្យសៀម និងពាក្យសំស្ក្រិត (ក្នុងនោះមានឲ្យឈ្មោះរុក្ខជាតិជាពាក្យឡាតាំងផង)។ ជាសន្និដ្ឋាន លោកយល់ថាពាក្យ "ផ្លាង៑" នេះ សំដៅលើស្បូវភ្លាំង ហើយម្យ៉ាងទៀតពាក្យនេះធ្លាប់ប្រទះឃើញនៅសិលាចារិកដទៃទៀតដែរ។

[៤០] កំណត់អ្នកប្រែ ៖ សិ សំដៅលើខ្ញុំប្រុសដែលនៅបម្រើតាមប្រាសាទ។ ជាទូទៅតែងសរសេរ សិ ដូច្នេះ តែក្នុងសិលាចារិកនេះ មានសរសេរជា ឝិ ឬ ឝី ទៀតផង។

[៤១] អ្នកធ្វើកិច្ចការនេះមានងារដូចជាបញ្ជិតព្រាហ្មណ៍ដែរ។

[៤២] "ផ្យាយ៑" ប្រហែលជាមុខងារអ្វីមួយ។

[៤៣] គោចន្ទត៑៖ ខ្ញុំពុំដឹងថាខ្មែរសព្វថ្ងៃហៅគោប្រភេទនេះថាដូចម្ដេចទេ។ ពាក្យ ចន្ទត៑ នេះ ច្បាស់ជាមានន័យថា "ពេញលេញ" ព្រោះឃើញថាផ្ទុយនឹងពាក្យ ក្រៀវ (ក្រៀវ) ច្បាស់ក្រឡែត។

[៤៤] កំណត់អ្នកប្រែ ៖ លោក Coedès ប្រែប្រឡូំ (ឬគេបោះពុម្ពប្រឡូំ) ថា ៤ នឹម។

[៤៥] ប្រហែលសំដៅថាជាសង្ខធម្មជាតិ។

[៤៦] សង្ខ័កាត់ពាក់កណ្ដាលហើយធ្វើពីសំរិតរបៀបនេះ ច្បាស់ជាត្រូវនឹងវត្ថុដែលយើងឃើញនៅរូប pl. XXXVI សៀវភៅBronzes khmèrs (Ars Asiatica, V) ហើយ។

[៤៧] វត្ថុទាំងបីនេះជាភាជន៍ ប្រើក្នុងកិច្ចពិធីដែលឃើញមាននិយាយញឹកញាប់នៅក្នុងសិលាចារិក។ អឃ៌្យ ជាថូម្យ៉ាងសម្រាប់ដាក់ទឹកថ្វាយព្រះ (អឃ៌្យប្រទាន)។ ពាក្យខ្មែរថា "អក" សំដៅលើភាជន៍តូចមានគ្រប ហើយគល់រាងប៉ោង (Groslier, Recherches, fig. 77 C, F) ក្នុងនោះមានអកកំបោរ ដែលប្រទះឃើញញឹកញាប់ជាងគេ។ "អក" នេះប្រហែលជាមកពីពាក្យ អឃ៌្យ ។ ពាក្យ បាទ្យ ប្រហែលជាសំដៅលើថូមួយដាក់ទឹកសម្រាប់លាងជើង។ រីឯន័យនៃពាក្យ វទ្ធិ៌ណី គឺពុំសូវច្បាស់ទេ។

[៤៨] នេះប្រហែលជាកូនឈើណាមួយក្នុងចំណោមកូនឈើសិប្បនិមិត្តដែលគេរៀបចំធ្វើជាសន្លឹកផ្កាប្រាក់ ដូចដែលតែងឃើញនៅក្បែរបល្ល័ង្កព្រះ នៅតាមវត្ត។ នៅស្រុកសៀម គេតម្រូវឲ្យស្ដេចនៃនគរចំណុះទាំងឡាយធ្វើកូនឈើមាសឬប្រាក់ជាសួយសារអាករ។ ផ្លាង៑ ប្រហែលជាផ្សេងគ្នាពី យផ្លាង៑ នៅបន្ទាត់លេខ១៤។ សព្វថ្ងៃ មានដើមឈើតូចម្យ៉ាងហៅថា "ភ្លាំង" ដែលមានស្លឹកស្រដៀងនឹងស្លឹក Laurier។

[៤៩] ប្រែពាក្យ លង្ហោ ថាស្លាន់នេះគឺនៅក្នុងការស្មាននៅឡើយ។ ឈ្មោះលោហៈនានានៅសម័យបុរាណមិនពិបាកស្គាល់ឡើយ ៖ មាស៑ (មាស), ប្រាក៑ (ប្រាក់), ត្របុ (សំណប៉ាហាំង), សំរិត (សំរិត)។ មានតែស្លាន់ទេ ដែលឈ្មោះហៅសព្វថ្ងៃពុំដែលឃើញមាននៅក្នុងសិលាចារិក ៖ ស្លាន់, ទង់ដែង, ទង់លង្ហិន ។ "ស្លាន់" ក្លាយមកពី "សុពណ៌" ដែលមានន័យថាមាស។ ទង់ដែង និង ទង់លង្ហិនជាពាក្យសៀម។

ស្រោម ស្រោប ៤ ធ្វើពីសំណប៉ាហាំង, វែក២[៥០], ត្បូលិ ២ *(?)*, បង្គងិ១ *(?)*, រាំងនទ១, ថូទឹក២, ថាន រុង៌២ *(?)*, ស្គរ១, តាល ចន្ទ *(?)*។ ស្រែ, ដី, ស្រុកភូមិទាំងអម្បាលម៉ានដែលព្រះរាជាធ្វើ សេចក្តី សម្រេចនេះ ទៅខាងកើតប្រសព្វ[៥១] នឹងគោលមួយ, ខាងអាគ្នេយ៍ប្រសព្វនឹងគោលមួយ, ខាងត្បូងប្រសព្វនឹង គោលមួយ, ខាងនិរតីប្រសព្វនឹងគោលមួយ, ខាងលិចប្រសព្វនឹងគោល មួយ, ខាងពាយព្យប្រសព្វនឹងគោលមួយ, ខាងជើងប្រសព្វនឹងគោលមួយ, ខាងឦសានប្រសព្វ នឹងគោលមួយ។

ភូមិអំបៅ[៥២] នេះដាក់ឲ្យនៅចំណុះបូជនីយដ្ឋានសុវណ៌លិង្គ។ *(ព្រះរាជា)* បានត្រាស់បង្គាប់ឲ្យយកទៅដូរនឹងភាជន៍ចម្អិនមួយទម្ងន់ ៣លិង៌ ហើយឲ្យយកស្រុកលុន៌ទៅដូរនឹងស្រុកទំទាំ ព្រមទាំងភូមិទាំងអស់ដែលនៅចំណុះស្រុកសម្ពុទ្ធិបុរ។ *(ព្រះរាជា)* បានត្រាស់បង្គាប់ឲ្យយក ស្រុក កនកភាគ ទៅដូរនឹងស្រុកចុង៌ថ្មិង៌ ព្រមទាំងឲ្យយកស្រុកវ្រះឦត៌ទៅដូរនឹង *(ដី)* ដែលគេព្រួសស្រូវនៅទីនោះ។

គី ខ្ចិត បន្ថែមលើនោះ[៥៣]៖ សារុបមកមាន ៩ ។

[៥០] វែកនេះមានរាងសំប៉ែត ឯដងវិញខ្លីបន្តិច។

[៥១] កំណត់អ្នកប្រែ ៖ សរសេរជា “ប្រសព្វ” *(ជួបគ្នា, ទៅប៉ះនឹង, ទៅទល់នឹង...)* ដូចសព្វថ្ងៃនេះ តាមពិតទៅខុសទេ។ ប៉ុន្តែបើសរសេរ “ប្រសប់” យោងទៅតាមខ្មែរបុរាណ ប្រសប៌ វិញ ឃើញថាទៅជាន់គ្នានឹងពាក្យ “ប្រសប់” មួយទៀតដែលមានន័យថា “ពូកែ, ប៉ិន...” ។

[៥២] ពិចារណាលើចំណុចត្រង់នេះ ឃើញហាក់ដូចថាទីកន្លែងសិលាចារិកនេះកាលពីសម័យនោះឈ្មោះថា អំបៅ ។

[៥៣] ពោលគឺបន្ថែមលើខ្ញុំបម្រើទាំង៨នាក់ដែលមានរាយឈ្មោះនៅខាងលើ *(បន្ទាត់១៤ដល់១៦)*។

# សិលាចារិកបាលីដែលចាស់ជាងគេនៅកម្ពុជា


សង្ខេប

*La plus ancienne inscription en pāli du Cambodge*

ដោយ George Coedès *(ប្រែសម្រួលដោយ អាំង ជូលាន)*

លោក George Coedès ផ្សព្វផ្សាយការសិក្សានេះនៅក្នុងទស្សនាវដ្តី BEFEO ឆ្នាំ១៩៣៧ ហើយចុះលេខ XXXII នៅក្នុងក្រុមអត្ថបទផ្សាយតគ្នាច្រើនឆ្នាំ ដែលមានចំណងជើងទូទៅថា “Etudes Cambodgiennes”។ នេះគឺសិលាចារឹកលេខ K.754 រកឃើញនៅគោកស្វាយចេក ហើយដែលមានពីរភាសា គឺបាលីនិងខ្មែរ។ សេចក្តីនោះចារនៅដើមស.វ.ទី១៤ មានន័យថាពុំមែនជាការចៃដន្យឡើយ ត្បិតចាប់ពីជំនាន់នោះមកសិលាចារឹកសំស្រ្កឹតលែងមានទៀតហើយ ដោយសារព្រះពុទ្ធសាសនាថេរវាទ ចាក់គ្រឹះមាំទាំនៅក្នុងសង្គមខ្មែរអំពីពេលនោះ ដោយប្រើបាលីជាភាសាយាន។



**Abstract**

*La plus ancienne inscription en pāli du Cambodge*

George Coedès (traslated by Ang Choulean)

This study, which we are publishing here for the first time in Khmer translation, was first published by George Coedès in number XXXII of the series entitled “Etudes cambodgiennes” (Cambodian Studies), in the *BEFEO* of 1937. It is a critical edition of the bi-lingual Pali-Khmer inscription of Kok Svay Chek (K. 754). As the title suggests, K. 754 constitutes the earliest appearance of the Pali language in text form in Cambodia. This is no coincidence as the date of composition, in the early 14th century, corresponds to the end of Sanskrit epigraphy in Cambodia. It was at this time that Theravada Buddhism, transmitted in Pali, was definitively established in the country.



**Résumé**

*La plus ancienne inscription en pāli du Cambodge*

George Coedès (traduit par Ang Chouléan)

Dans la série intitulée « Etudes cambodgiennes », George Coedès porta au numéro XXXII cette étude qu’il publia dans le *BEFEO* de 1937, ici traduite en khmer. C’est une édition de l’inscription bilingue pâli-khmère de Kôk Svay Chek (K. 754). Pour ce qui est du pāli, comme l’indique le titre, il s’agit bien d’une toute première apparition connue à ce jour de cette langue en tant que texte. Le début du 14ème siècle, date de sa rédaction, n’est pas le fait du hasard, car il correspond à la fin de l’épigraphie sanskrite du Cambodge. Le theravâda, véhiculé par le pāli, marque ici son implantation définitive.